Reading Book

ពិភពរឿងនិទាន

The World of Stories

# រឿង ពស់ថ្លាន់ក្អួតពិស

# Python Belching out Venom



សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge

កាលពីព្រេងនាយ មានប្តីប្រពន្ធពីរនាក់ទើបនឹងរៀបការហើយ ថ្មីៗ។ ថ្ងៃមួយ បុរសជាប្តីបាននាំប្រពន្ធទៅលេងផ្ទះឪពុកម្តាយនៅឯភូមិមួយផ្សេងទៀត។

Once upon a time, there lived a newlywed. One day the husband toke his wife to visit his parents living in another village.



ពេលនោះ   មានពស់ថ្លាន់មួយលូនចេញពីក្នុងព្រៃឆ្លងកាត់ផ្លូវនេះ បានឃើញដានជើងមនុស្ស ក៏ខំលិឍដានជើងទាំងនោះដើម្បីបញ្ជាក់ពីរិទ្ធិអំណាចដ៏ខ្លាំងក្លារបស់ខ្លួន។

At that time, a python crawled out of the forest into the path and saw the couple's footprints. To confirm the great power of its venom, the python licked the couple's footprints.



ដោយសារតែអំណាចខ្លាំងពូកែអស្ចារ្យរបស់ពស់ថ្លាន់ ទាំងពីរនាក់ប្តីប្រពន្ធនោះ ក៏ស្លាប់បន្ទាប់ពីបានទៅដល់ផ្ទះឪពុកម្តាយរបស់ពួកគេ។

Due to its greatly powerful venom, the couple died after arriving at their parents' house.



ឪពុកម្តាយព្រមទាំងបងប្អូនញាតិសន្តានទាំងអស់ អង្គុយយំសោក សង្រេងអាឡោះអាល័យគ្រប់ៗគ្នា។ ហើយក៏នាំគ្នាធ្វើបុណ្យសព ឱ្យពួកគេតាមទំនៀមទំលាប់ប្រពៃណី។

Their parents along with all the relatives wailed and grieved for them. Then they arranged the couple's funeral according to the tradition.



ដើម្បីបញ្ជាក់ពីភាពអស្ចារ្យ និងរិទ្ធិអំណាចនៃពិសរបស់ខ្លួន ពស់ថ្លាន់ក៏សួរធ្វើពើទៅសត្វក្អែកថា "បងក្អែកៗ! ខ្ញុំឮសូរមាត់មនុស្ស អឺក៏អ៊ូអរខ្លាំងម្ល៉េះនៅក្នុងភូមិនេះ?"

To show off the great power of its venom, the python pretentiously asked a crow, "Brother Crow! I heard humans talking so noisily in the village?"



ក្អែកឆ្លើយថា "ពួកគេកំពុងតែសើចសប្បាយទេតើ! ព្រោះគេធ្លាប់ដឹងថា ពិសបងថ្លាន់ឯងនេះពូកែខ្លាំងណាស់ គ្រាន់តែលិឍដានជើងរបស់គេក៏ស្លាប់បានដែរ។ តែឥឡូវបែរជាមិនស្លាប់ទៅវិញ ទើបគេនាំគ្នាសើចសប្បាយរីករាយទាំងអស់គ្នាទៅ"។

The crow responded, "They are actually laughing because they always know that your venom is so powerful. Just licking their footprints, you can cause their death. However, now the couple does not die; that is why they are all laughing joyfully."



ពស់ថ្លាន់ឮដូច្នោះគិតក្នុងចិត្តថា "ពិសរបស់អញធ្លាប់តែពូកែឆុតឆាប់ បើឥឡូវលែងសក្ដិសិទ្ធិទៀតហើយនោះ ទុកវាធ្វើអ្វីទៀតទៅ ត្រូវតែក្អែចោលឱ្យអស់"។

Hearing that, the python pondered silently, "My venom is always so powerful; and if it is no longer so, I do not want to keep it anymore. I will belch up all my venom."



បន្ទាប់មក ពស់ថ្លាន់ដែលចូលចិត្តអួតក្អេងក្អាងនោះ ក៏ក្អែពិស
របស់ខ្លួនចេញចោលគ្មានសល់។

After that, the extremely boastful python started to belch up all its venom.



ពពួកសត្វដែលបានដឹងថាពស់ថ្លាន់ក្អែពិសនោះគឺ ត្រី ពស់ ក្អែប ខ្ទួយ សង្ការ ស្រាំង ឪម៉ាល់ជាដើម ដែលនាំគ្នាលូន ឬហើរមកដណ្ដើមយកពិសរបស់ពស់ថ្លាន់គ្រប់ៗគ្នា ខ្លះបានច្រើន ខ្លះបានតិច ខ្លះទៀតក៏មិនបានដោយមកមិនទាន់គេ។



All the animals that learned about the venom belch out were fishes, other types of snakes, centipedes, scorpions, Sang Ar (a type of black ant with powerful sting), wasps, and hornets; they crawled or flied to get the python's venom. Some animals got lots of venom and others got a little, while the rest got nothing due to their lateness.



ពស់ដែលបានពិសច្រើនជាងគេគឺ ពស់ព្រលិត ពស់ចន្ទទ្រមម ពស់ដី ពស់ប្រេង ពស់ត្រី ពស់ព្រៃ ពស់ខ្សែគោ ពស់កុក និង ពស់សម្លាប់កង្កែប។

The types of snakes that got a lot of venom are Puos Pralit snakes, Puos Chan Tramam snakes, Puos Dey snakes, Puos Preng snakes, Puos Trey snakes, Puos Khsekau snakes, Puos Kok snakes, and Puos Samlab Kangkeb snakes.



ពពួកពស់ទាំងនេះយកពិសថ្លាន់បានច្រើនជាងគេ។ ហេតុនេះហើយ បានជាពួកវាឥឡូវនេះ ចឹកមនុស្សមិនស្លាប់ ហើយគ្មានការឈឺចាប់អ្វីទាល់តែសោះ ព្រោះពិសថ្លាន់នេះ បើប្រើច្រើនពេកត្រឡប់ជាគ្មានពិសទៅវិញ។

These types of snakes got most of the python's venom, and that is why their biting cannot kill humans and causes no pain at all because when too much venom of the python is used, such amount of venom become harmless.



ពពួកពស់ដែលយកពិសថ្លាន់បានតិចល្មមនោះគឺ ពស់វែកដំបូក ពស់វែករនាម ពស់វែកស្រងែ ពស់វែកក្របីជាដើម។ ហេតុនេះហើយ បានជាពពួកសត្វពស់ទាំងអស់នេះ មានពិសពូកែខ្លាំងជាងគេ បើបានចឹកហើយ កម្រនឹងរស់ ឬព្យាបាលបានឡើយ។



The types of snakes that got a little venom from the python are Puos Vek Dambok snakes, Puos Vek Roniem snakes, Puos Vek Sraghe snakes, and Puos Vek Krabey snakes, so these types of snakes are so harmful. If one get bitten by the snakes, they can seldom survive or be cured.



ចំណែកពពួកត្រីអណ្ដែង ត្រីកញ្ចុះ ត្រីឆ្លាំង ឬសត្វខ្ទួយ ក្អែប ខ្យាដីរ ស្រមោច សង្អារ ស្រាំង ឪម៉ាល់ ឃ្មុំ ព្រួតដែលទៅក្រោយគេ ក៏ប្រមូលបានពិសដែលនៅសេសសល់ យកមកប្រលាក់ចុងធ្នុង រីទ្រនិចរៀងៗខ្លួន។ ហេតុនេះហើយ បានជាពពួកសត្វទាំងអស់នេះ មានពិសតិចតួចមកដល់សព្វថ្ងៃនេះ។



Catfish, Trey Kanh Chas fish, Trey Chhlaing fish, scorpions, centipedes, ants, Sang Ar (a type of black ants with a powerful sting), wasps, hornets, and bees which arrived later than the others got the little remaining venom to apply on their barbs or stings. That is why these animals have little venom up to date.



រីឯត្រីក្រម៉ម និង ត្រីពោមកមិនទាន់គេខឹងខ្លាំងណាស់ ព្រោះ ដណ្តើមពិសមិនបាន ក៏ហាមាត់ស្រែកយំទាល់តែហើមមុខស្តុល។ ឯត្រីសណ្តាយវិញ ឃើញត្រីក្រម៉ម និង ត្រីពោយំស្រែកដូច្នេះ ក៏សើចក្អាកក្អាយមិនឈប់ ទាល់តែរយះមាត់យ៉ាងធំ។

Trey Kramam fish and Trey Po fish arrived too late and got so furious because they could not get any venom. Then the two types of fishes cried so long that their face swelled so big. Trey Sanday fish that saw Trey Kramam fish and Trey Po fish cry like that laughed so relentlessly that their mouse tore apart widely.



ហេតុនេះហើយ បានជាត្រីក្រម៉ម និងត្រីពោមានមុខធំស្ពុល ដូច្នេះ។ ឯត្រីសណ្ដាយវិញ មានរង្វះមាត់វែងច្រវាបរហូតមកដល់បច្ចុប្បន្ននេះ។

As a result, Trey Kramam fish and Trey Po fish have such swollen face, and Trey Sanday fish have wide mouth opening up to date.



ចំណែកពស់ថ្លាន់ ក៏លែងមានរិទ្ធិអំណាចតទៅទៀតដែរ។ ព្រោះវាបានចាញ់ឧបាយកលរបស់សត្វក្អែក។ ចាប់តាំងពីពេលនោះមក មនុស្សទាំងអស់មិនដែលព្រួយបារម្ភខ្លាចមានគ្រោះថ្នាក់ដោយសារពស់ថ្លាន់រហូតមកដល់សព្វថ្ងៃនេះ។ **ចប់**

"កុំសប្បាយនៅក្នុងសេចក្តីទុក្ខព្រួយរបស់អ្នកដទៃ"

About Pythons, they are no longer harmful because they were deceived by the crow. Since then all humans have never worried about the danger caused by pythons until today. **The end**

"Do not have the pleasure in the misfortune of others."

